បេឡាជាតិសន្តិសុខសង្គម
National Social Security Fund



ព្រឹត្តិបត្រព័ត៌មានបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. ឆ្នាំទី១៣ | លេខ៣២ ឆ្នាំ២០២២

ធានាសន្តិសុខប្រាក់ចំណូល
រួមចំណែកកាត់បន្ថយភាពក្រីក្រ
លើកកម្ពស់ស្ថិរភាពសង្គម

ព្រឹត្តិបត្រព័ត៌មាន

# ប.ស.ស.

## មាតិកា


០១ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង៖ បើទោះបីជាស្ថិតក្នុងស្ថានភាព......០១
០២ ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. បើកកិច្ចប្រជុំលើកទី១១............០៤
០៣ ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. បន្តកិច្ចប្រជុំ ដើម្បីពិនិត្យ...........០៧
០៤ យើងទាំងអស់គ្នាពិតជាមានសំណាងមានមគ្គុទ្ទេសក៍ដឹកនាំ.........០៩
០៥ សេចក្តីព្រាងប្រកាសចំនួន ២ ត្រូវបានលើកយកមកប្រជុំ...........១២
០៦ កិច្ចប្រជុំ ស្តីពីជម្រើសកំណែទម្រង់របបប្រាក់សោធនសម្រាប់ ......១៤
០៧ ឯកឧត្តមអគ្គនាយក ប.ស.ស.៖ ដើម្បីឲ្យការដាក់ដំណើរការរបប...១៦
០៨ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ១៩
០៩ ការដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់ គឺជាគន្លឹះ......២២
១០ អ្នកបើកបរយានយន្តដឹកកម្មករ និងបងប្អូនកម្មករនិយោជិត.........២៤
១១ នាយកដ្ឋានគោលនយោបាយសន្តិសុខសង្គម នៃ ប.ស.ស. .......២៧
១២ មន្ត្រី និងបុគ្គលិកនៃនាយកដ្ឋាន សេវាអតិថិជន និងទំនាក់ទំនង...២៩
១៣ ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស ប.ស.ស. ចូលរួមកិច្ចប្រជុំ..........៣១
១៤ តំណាង ប.ស.ស. កម្ពុជា ចូលរួមក្នុងវេទិកាស្តីពី សន្តិសុខសង្គម..៣២
១៥ មន្ត្រីជំនាញ ប.ស.ស. ជាច្រើនរូបចូលរួមកិច្ចប្រជុំស្តីពី គម្រោង....៣៤
១៦ វគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់........៣៥
១៧ មន្ត្រីជំនាញនៃ ប.ស.ស.ជួបប្រជុំពិភាក្សាជាមួយទីភ្នាក់ងារបារាំង..៣៦
១៨ ជាង ៣២០ស្ថាប័ន ដែលមកពី ១៦០ប្រទេស ផ្សេងៗគ្នា ..........៣៨
១៩ ឯកឧត្តម ហេង សុជាន់ណារិទ្ធ អគ្គនាយករង ប.ស.ស. ដឹកនាំ.....៤០
២០ ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស ប.ស.ស. ចូលរួមកិច្ចប្រជុំ.........៤២
២១ ថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមឈ្វេង...៤៤
២២ ពងទាកូនជួយសុខភាព តែបើហ៊ានញ៉ាំខុសនឹងគ្រោះថ្នាក់ដល់.....៤៥
២៣ បណ្តាំ អ្នកព្រះភិរម្យភាសា អ៊ូ ហៅង៉ុយ...................................៤៦








### រចនាសម្ព័ន្ធព្រឹត្តិបត្រ

**ឯកឧត្តម អ៊ុក សមវិទ្យា**
**អគ្គនាយក ប.ស.ស.**

| | |
|---|---|
| ចាងហ្វាង | ឯកឧត្តមបណ្ឌិត ហេង សុជាន់ណារិទ្ធ |
| និពន្ធនាយក | លោក អ៊ុក សំអូន |
| និពន្ធនាយករង | លោកស្រី ចាន់ ស៊ីណូន |
| | លោក ឃុន វិចិត្រ |
| | លោក វ៉ាន់ ចាន់ថន |
| លេខានិពន្ធ | លោក នាង ជូ |
| | លោក យន គន្ធា |
| | លោក អ៊ឹង លាងឆុង |
| | លោក យង់ សុខន |
| ផ្នែកការីកុំព្យូទ័រ | លោក អ៊ុង ស៊ីខឿ |
| | លោក តូង គឹម លាង |
| | លោក ថេត ពិសិដ្ឋ |

# ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បើទោះបីជាស្ថិតក្នុងស្ថានភាពដ៏លំបាកក្នុងបរិបទកូវីដ-១៩ តែ ប.ស.ស.នៅតែសម្រេចបានលទ្ធផលការងារយ៉ាងល្អប្រសើរក្នុងឆ្នាំ២០២១ កន្លងមកនេះ




ក្នុងឱកាសអង្គសន្និបាតបូកសរុបលទ្ធផលការងារសម្រេចបានប្រចាំឆ្នាំ-២០២១ និងទិសដៅការងារឆ្នាំ២០២២ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានថ្លែងនូវការកោតសរសើរ និងវាយ-តម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ របស់បេឡាជាតិសន្តិសុខ-សង្គម (ប.ស.ស.) ដែលបានអនុវត្តការ-ងារកន្លងមក ក្នុងការបម្រើសេវាសង្គមជូនដល់សមាជិក ប.ស.ស. របស់ខ្លួន













ប្រកបដោយភាពទន់ភ្លន់ ជាមួយនឹងក្រមសីលធម៌ មនសិការវិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់ រហូតសម្រេចបានលទ្ធផលល្អប្រសើរ បើទោះបីជាស្ថិតក្នុងស្ថានភាពដ៏លំបាក នៃការរីករាលដាលនៃជំងឺកូវីដ-១៩ យ៉ាងណាក៏ដោយ។

ជាមួយគ្នានឹងការថ្លែងឡើងខាងលើនេះផងដែរ **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកទាំងអស់នៃ ប.ស.ស. ដែលបានសហការខិតខំបំពេញការងារជាមួយក្រសួង ស្ថាប័នអង្គភាពពាក់ព័ន្ធនានា រួមទាំងអង្គការជាតិ និងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ទាំងអស់ រហូតទទួលបានសមិទ្ធផលយ៉ាងគាប់ប្រសើរនាពេលនេះ ដែលបានរួមចំណែកគ្រប់សកម្មភាព ក្នុងការពង្រឹង និងអភិវឌ្ឍន៍យ៉ាងសកម្មលើវិស័យសន្តិសុខសង្គម-កម្ពុជា និងជាផ្នែកដ៏ធំក្នុងការលើកកម្ពស់ជីវភាពប្រជាជនកម្ពុជាឲ្យកាន់តែល្អប្រសើរឡើង ឆ្លើយតបទៅនឹងគោលនយោបាយជាតិគាំពារសង្គម ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជា-ណាចក្រកម្ពុជា។

ក្នុងឱកាសសន្និបាតនេះដែរ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. បានថ្លែងបញ្ជាក់ថា៖ បច្ចុប្បន្នបេឡាជាតិសន្តិសុខសង្គម បានដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារ ទាំងវិស័យ-ឯកជន និងវិស័យសាធារណៈ។ ក្នុងនោះសម្រាប់វិស័យឯកជនបានចុះបញ្ជីសរុបចំនួន ១៧ ៣១៧សហគ្រាស ដែលមានសមាជិកសរុបចំនួន ២ ៣០៥ ៩៥៨នាក់ និងផ្នែកថែទាំសុខភាពចំនួន ១៤ ៦៨៩ សហគ្រាសមានសមាជិកចំនួន ២ ៣០៥-៩៥៨នាក់។ ចំណែកវិស័យសាធារណៈបានចុះបញ្ជីផ្នែកថែទាំសុខភាព សរុប-ចំនួន ៣៨ស្ថាប័ន មានសមាជិកសរុប-៣៩៨ ៧៤០នាក់ និងផ្នែកហានិភ័យ-ការងារ ចំនួន ៣៥ស្ថាប័ន មានសមាជិកសរុប ២៤៨ ៨៩២នាក់។









**ឯកឧត្តមអគ្គនាយក** បានថ្លែងបន្ថែមទៀតថាៈ ក្នុងឆ្នាំ២០២១ កន្លងទៅនេះ ប.ស.ស. បានអនុវត្តបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនទាំងក្នុង និងក្រៅប្រព័ន្ធ សរុបជាទឹកប្រាក់ចំនួន ២៦.២២ ប៊ីលានរៀល និងផ្តល់តាវកាលិកជូនសមាជិករបស់ខ្លួនចំពោះផ្នែកហានិភ័យការងារសរុបជាទឹកប្រាក់ចំនួន ១០.៦៨ ប៊ីលានរៀល និងផ្នែកថែទាំសុខភាពសរុបជាទឹកប្រាក់ចំនួន ១៥៦.២០ ប៊ីលានរៀលផងដែរ។











# ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. បើកកិច្ចប្រជុំលើកទី១១ អាណត្តិទី១ ដើម្បីពិនិត្យ និងពិភាក្សា លើរបៀបវារៈមួយចំនួនដែលបានគ្រោងទុក

បន្ទាប់ពីមានកិច្ចប្រជុំពិភាក្សាត្រួតពិនិត្យពីថ្នាក់ដឹកនាំ និងក្រុមកិច្ចការអ្នកច្បាប់ នៃ ប.ស.ស. ជាច្រើនលើកកន្លងមក **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ បើកកិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. ដើម្បីពិនិត្យ និងកែសម្រួលលើសេចក្តី-ព្រាងប្រកាសចំនួន២ ដែលរួមមាន៖ ១.សេចក្តីព្រាងប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសពនៃរបប













សន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និង ២.សេចក្តីព្រាងប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

ថ្លែងទៅកាន់អង្គប្រជុំ**ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** បានលើកសំណើដាក់ជូនសមាជិកក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. ទាំងអស់ពិនិត្យ និងពិភាក្សា ព្រមទាំងកែសម្រួលប្រកបដោយការយកចិត្តទុកដាក់ខ្ពស់លើសេចក្តីព្រាងប្រកាសខាងលើ ដើម្បីពង្រឹងការអនុវត្តវិធានការច្បាប់ និងពង្រឹងយន្តការអនុវត្តការងារព្រមទាំងរក្សាតម្លាភាព លើកកម្ពស់គុណភាព ប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈរបស់បេឡាជាតិសន្តិសុខសង្គម ឲ្យកាន់តែមានភាពល្អប្រសើរ ត្រឹមត្រូវ និងច្បាស់លាស់ ប្រកបដោយចីរភាព ស្របតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម។

















បន្ទាប់ពីក្រុមប្រឹក្សាភិបាល ប.ស.ស. បានប្រជុំពិនិត្យ និងពិភាក្សា ពេញមួយព្រឹកនេះ សេចក្តីព្រាងប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសព នៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលមាន ៣ជំពូក ៧ប្រការ ត្រូវបានក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. អនុម័តទាំងស្រុង ដោយឡែកសេចក្តីព្រាងប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលមាន ៧ជំពូក ២២ប្រការ បានពិនិត្យ និងកែសម្រួល ២ជំពូក និង ៧ប្រការរួចរាល់ ចំពោះចំណុចដែលនៅសេសសល់ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. នឹងលើកកិច្ចប្រជុំពិភាក្សានាពេលក្រោយទៀតតាមការគ្រោងទុក។

ជាមួយគ្នានោះដែរ **ឯកឧត្តមបណ្ឌិត រដ្ឋមន្ត្រី** ក៏បានធ្វើការកោតសរសើរយ៉ាងស្មោះចំពោះការខិតខំប្រឹងប្រែង និងការសហការយ៉ាងល្អ របស់ក្រុមប្រឹក្សាភិបាល ប.ស.ស. ព្រមទាំងការខិតខំប្រឹងប្រែង របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ ប.ស.ស. ដែលបានខិតខំយកចិត្តទុកដាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តការងារកន្លងមក បើទោះបីស្ថិតក្នុងស្ថានភាពដ៏លំបាកនៃការរាតត្បាតនៃជំងឺកូវីដ-១៩ យ៉ាងណាក្តី ក៏ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ប.ស.ស. នៅតែបំពេញតួនាទីយ៉ាងល្អក្នុងការផ្តល់សេវាសាធារណៈប្រកបដោយភាពទន់ភ្លន់ ក្រមសីលធម៌ មនសិការវិជ្ជាជីវៈ និងមានស្មារតីទទួលខុសត្រូវខ្ពស់ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣។

សូមបញ្ជាក់ថា កិច្ចប្រជុំក្រុមប្រឹក្សាភិបាលខាងលើ ប្រព្រឹត្តទៅនាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៤ ខែមីនា ឆ្នាំ២០២២ នៅសាលប្រជុំធំ ស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានវត្តមានអញ្ជើញចូលរួមពីសំណាក់សមាជិកនៃក្រុមប្រឹក្សាភិបាល និងសមាជិកសមាជិកាសរុបប្រមាណជាង ១០រូប។





# ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. បន្តកិច្ចប្រជុំ ដើម្បីពិនិត្យ និងពិភាក្សា លើរបៀបវារៈ ដែលនៅសេសសល់ កាលកិច្ចប្រជុំលើកទី១១ របស់ខ្លួន

**ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃ ប.ស.ស. បានអញ្ជើញជាអធិបតីភាព បើកកិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃប.ស.ស. លើកទី១២ អាណត្តិទី១ ដើម្បីបន្តពិនិត្យ និងកែសម្រួលលើជំពូក៣ ប្រការ៨ នៃ សេចក្តីព្រាងប្រកាសស្តីពីបែបបទ និង នីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅ ក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ













ដែលនៅសេសសល់កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ កន្លងមក។

បន្ទាប់ពីក្រុមប្រឹក្សាភិបាល ប.ស.ស. បានប្រជុំពិនិត្យ និងពិភាក្សាអស់រយៈពេលពេញមួយព្រឹក សេចក្តីព្រាងប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលមាន ៧ជំពូក ២២ប្រការ ត្រូវបានក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. អនុម័តទាំងស្រុង។

សូមបញ្ជាក់ថា កិច្ចប្រជុំក្រុមប្រឹក្សាភិបាលខាងលើ ប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ទី៣១ ខែមីនា ឆ្នាំ២០២២ នៅសាលប្រជុំធំ ស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានវត្តមានអញ្ជើញចូលរួមពីសំណាក់សមាជិកនៃក្រុមប្រឹក្សាភិបាលសរុបចំនួន ១១រូប៕










# យើងទាំងអស់គ្នាពិតជាមានសំណាងមានមគ្គុទ្ទេសក៍ ដឹកនាំប្រទេសប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃខ្ពង់ខ្ពស់បំផុត

បច្ចុប្បន្នស្ថានភាពជំងឺកូវីដ១៩ បំប្លែងថ្មីអូមីក្រុងកំពុងធ្វើឲ្យប្រជាជនតាមបណ្តាប្រទេសមួយចំនួនលើសកលលោកនូវតែមានការភ័យខ្លាចពីការឈឺស្លាប់ដោយសារការឆ្លងរីករាលដាលនូវជំងឺដ៏កំណាចមួយនេះ មិនថាប្រទេសនោះធំតូច មាន ក្រនោះឡើយ។

នេះបើតាមអនុសាសន៍ **ឯកឧត្តម អ៊ឹក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម បានថ្លែងឡើងនៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែធ្នូ និងដាក់ចេញនូវផែនការអនុវត្តការងារបន្តជាមួយថ្នាក់ដឹកនាំនាយកដ្ឋាន និងប្រធានសាខា ប.ស.ស. ខេត្ត-ខណ្ឌ ទាំងអស់នៃ ប.ស.ស.។

**ឯកឧត្តម អ៊ឹក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលបានថ្លែងបញ្ជាក់ថា៖ យើងទាំងអស់គ្នាពិតជាមានសំណាងណាស់ដែលមានមគ្គុទ្ទេសក៍ដឹកនាំប្រទេសប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃខ្ពង់ខ្ពស់បំផុតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដែលបានដាក់ចេញនូវយុទ្ធសាស្ត្រចាក់ស្រោចវ៉ាក់សាំងជូនពលរដ្ឋទូទាំងប្រទេសដើម្បីទប់ស្កាត់











នៃការរីករាលដាលនៃជំងឺកូវីដ-១៩ នេះ ហេតុកម្ពុជាទទួលបានជោគជ័យ និងបានកំពុងដាក់ឲ្យបើកដំណើរការឡើងវិញលើគ្រប់វិស័យផងដែរ។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានបន្តថាៈ ដូច្នេះក្នុងនាមយើងជាអ្នកបម្រើសេវាជូនប្រជាជន ពិសេសសមាជិករបស់ខ្លួន ទាំងថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកទាំងអស់ ពិតជាមានកិត្តិយស និងមិនអាចភ្លេចពីការដឹងគុណបំផុតចំពោះមគ្គុទ្ទេសក៍ដឹកនាំប្រទេសប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃខ្ពង់ខ្ពស់បំផុតនៃយើងបានឡើយ។

ឆ្លើយតបទៅនឹងគុណូបការគុណដ៏ថ្លៃថ្លានេះ យើងទាំងអស់គ្នាគប្បីប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ ក្រមសីលធម៌ល្អក្នុងការដឹកនាំអនុវត្តការងារប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ ក្នុងការបំពេញកិច្ចការដោយធ្វើយ៉ាងណាឲ្យការអនុវត្តការងារកាន់តែមានប្រសិទ្ធភាព ទទួលបានលទ្ធផលខ្ពស់ និងបានអំពាវនាវឲ្យមន្ត្រី និងបុគ្គលិក បន្តរស់នៅតាមគន្លងប្រក្រតីថ្មីដោយត្រូវគោរពអនុវត្ត នូវវិធានសុខាភិបាល ក្រោមការដាក់ចេញ ពីសំណាក់ប្រមុខដឹកនាំ នៃរាជរដ្ឋាភិបាលកម្ពុជា ពិសេសត្រូវអនុវត្តនូវវិធាន ៣ការពារ និង ៣កុំ ឲ្យបានជាប់ជានិច្ច ក្នុងន័យរួមចំណែក











ទប់ស្កាត់ ការឆ្លងរីករាលដាលជំងឺកូវីដ-១៩។

ជាមួយគ្នានេះ **ឯកឧត្តមប្រតិភូ** បានជំរុញលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ លោក លោកស្រីជា ប្រធាន អនុប្រធាន និងមន្ត្រី បុគ្គលិក ប.ស.ស. គ្រប់នាយកដ្ឋាន និងគ្រប់សាខាទាំងអស់ត្រូវបន្តពន្លឿន ការដោះស្រាយបញ្ហាផ្សេងៗដែលនៅសេសសល់ក្នុងឆ្នាំចាស់ឲ្យអស់។ ក្នុងនោះ ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃ និងប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីសម្រាលកូន ឲ្យទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ពិសេសការផ្តល់ការសម្រប សម្រួលឲ្យទាន់ពេលវេលាចំពោះបងប្អូនដែលជាសមាជិក ប.ស.ស. ពេលទៅទទួលសេវានៅតាមមូលដ្ឋានសុខាភិបាល ដែលជាដៃគូ ប.ស.ស.។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំផ្ទៃក្នុងខាងលើ ប្រព្រឹត្តទៅនាព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ នៅសាលប្រជុំធំនៃ ប.ស.ស. ស្នាក់ការកណ្តាលរាជធានីភ្នំពេញ ដោយមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ ព្រមទាំងលោក លោកស្រី ដែលជាប្រធាន អនុប្រធានសាខា ប.ស.ស. ខេត្ត-ខណ្ឌ សរុបប្រមាណជាង ១០០នាក់ ទាំងតាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting) និងដោយផ្ទាល់។














# សេចក្តីព្រាងប្រកាសចំនួន ២ ត្រូវបានលើកយកមកប្រជុំត្រួតពិនិត្យកែសម្រួល

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បានអញ្ជើញជាអធិបតីភាព ក្នុងកិច្ចប្រជុំត្រួតពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងប្រកាសចំនួន២ គឺសេចក្តីព្រាង-ប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសពនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងសេចក្តីព្រាងប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហ-គ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ បន្ទាប់ពីក្រុមការងារកិច្ចការច្បាប់ នៃ ប.ស.ស. បានប្រជុំរួចរាល់។

**ឯកឧត្តមប្រតិភូ** បានថ្លែងឡើងថា៖ នេះជាការយកចិត្តទុកដាក់មួយចំណែកបន្ថែមទៀត នៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ដែល ប.ស.ស. បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសពនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននេះឡើង ដើម្បីធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធិផលនៃការអនុវត្តរបបសន្តិសុខសង្គម











ព្រមទាំងជួយសម្រាលនូវទុក្ខលំបាករបស់សិទ្ធិវន្តនៃវិភាជន៍បូជាសព នៃសោធនិកជរាភាព ឬសោធនិកទុព្វលភាព។

ជាមួយគ្នានេះ **ឯកឧត្តមប្រតិភូ** ក៏បានស្នើដល់សមាជិកនៃអង្គប្រជុំទាំងអស់ ត្រូវពិភាក្សារាល់បញ្ហាប្រឈមផ្សេងៗឲ្យបានគ្រប់ជ្រុងជ្រោយបន្ថែមទៀត ដើម្បីឲ្យប្រកាសទាំងពីរនេះ កាន់តែមានលក្ខណៈល្អប្រសើរ និងត្រឹមត្រូវស្របទៅតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម ដោយធ្វើយ៉ាងណាធានាបាននូវប្រសិទ្ធភាពខ្ពស់ប្រកបដោយចីរភាព។

បន្ទាប់ពីបានប្រជុំពិភាក្សាពេញមួយព្រឹក **ឯកឧត្តមប្រតិភូ** បានសម្រេចអនុម័តទាំងស្រុងទៅលើសេចក្តីព្រាងប្រកាសទាំងពីរខាងលើ និងរៀបចំដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ដើម្បីពិនិត្យសម្រេចបន្ត។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំពិភាក្សាខាងលើ ប្រព្រឹត្តទៅនៅថ្ងៃអង្គារ ទី១ ខែកុម្ភៈ ឆ្នាំ២០២២ នៅសាលប្រជុំធំទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានវត្តមានអញ្ជើញចូលរួមពីសំណាក់ប្រធាន សមាជិក សមាជិកានៃក្រុមការងារកិច្ចការច្បាប់ នៃ ប.ស.ស. ព្រមទាំងលោក លោកស្រី ប្រធាននាយកដ្ឋាន សរុបប្រមាណជាង ២០រូប៕














# កិច្ចប្រជុំ ស្តីពីជម្រើសកំណែទម្រង់របបប្រាក់សោធនសម្រាប់ មន្ត្រីសាធារណៈ និងផែនការការងារស្តីពី ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុ និងការវិនិយោគ

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ក្នុងឱកាសអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំស្តីពីជម្រើសកំណែទម្រង់របបប្រាក់សោធនសម្រាប់មន្ត្រីសាធាណៈ និងផែនការការងារស្តីពី ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុ និងការវិនិយោគ **ឯកឧត្តមប្រតិភូ** បានថ្លែងឡើងថា៖ កំណែទម្រង់របបប្រាក់សោធនសម្រាប់មន្ត្រីសាធារណៈ និងផែនការការងារស្តីពីការវាយតម្លៃហានិភ័យហិរញ្ញវត្ថុ និងការវិនិយោគនេះ គឺដើម្បីគាំទ្រដល់ការអភិវឌ្ឍរបស់ ប.ស.ស. និងការអនុវត្តប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា ឲ្យកាន់តែទូលំទូលាយតាមរយៈការកសាងសមត្ថភាព និងការផ្លាស់ប្តូរចំណេះដឹង ដែលនឹងបំពេញការងារដទៃទៀតរបស់អង្គការអន្តរជាតិខាងការងារ (ILO) ស្តីពីកិច្ចគាំពារសង្គម។
















តាមរយៈគម្រោងផែនការពាក់ព័ន្ធនឹងការវាយតម្លៃហានិភ័យហិរញ្ញវត្ថុ និងការវិនិយោគនេះ **ឯកឧត្តមប្រតិភូ** បានបញ្ជាក់ឲ្យដឹងថា៖ កន្លងមក ប.ស.ស. បានទទួលវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញចំនួន ៣ដង ក្នុងឆ្នាំ២០២១ ពីអង្គការអន្តរជាតិខាងការងារ (ILO) ពាក់ព័ន្ធទៅនឹងផ្នែកវិនិយោគមូលនិធិសន្តិសុខសង្គម និងការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ ការគ្រប់គ្រងទិន្នន័យសម្រាប់ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុ និងផែនការយុទ្ធសាស្រ្តវិនិយោគ ធៀបនឹងការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ ធៀបនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ផងដែរ។

គួរបញ្ជាក់ថា៖ ក្នុងកិច្ចសហការដ៏ល្អជាមួយ ប.ស.ស. កន្លងមក និងយោងតាមស្មារតីនៃអង្គប្រជុំខាងលើ អង្គការអន្តរជាតិខាងការងារ (ILO) បានស្នើសុំពិភាក្សាបន្ថែមជាមួយក្រុមការងារ ប.ស.ស. ជាពិសេសជាមួយ **ឯកឧត្តមប្រតិភូ** ដើម្បីឈ្វេងយល់នូវការគាំទ្រដែល ប.ស.ស. ត្រូវការពីអង្គការអន្តរជាតិខាងការងារ (ILO) និងស្នើសុំការឯកភាពពាក់ព័ន្ធនឹងផែនការការងារខាងលើ និងផែនការការងារលម្អិតសម្រាប់ការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការវាយតម្លៃហានិភ័យហិរញ្ញវត្ថុ មុនពេលឈានដល់ការអនុវត្តផែនការការងារខាងលើនេះ។

ឆ្លៀតក្នុងឱកាសជាមួយគ្នានេះដែរ **ឯកឧត្តមប្រតិភូ** ក៏បានស្នើសុំអង្គការអន្តរជាតិខាងការងារ (ILO) ក្នុងការផ្តល់អ្នកប្រឹក្សាយោបល់ ដើម្បីជួយដល់ដំណើរការរៀបចំផែនការសកម្មភាពលម្អិតនៃការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ICT) ថ្មី នៃគម្រោងទំនើបភាវូបនីយកម្មដំណាក់កាលទី២ របស់ ប.ស.ស. ផងដែរ។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំខាងលើប្រព្រឹត្តទៅនៅព្រឹកថ្ងៃចន្ទ ទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ នៅសាលប្រជុំធំ ស្នាក់ការកណ្តាល រាជធានីភ្នំពេញ ដោយមានការចូលរួមពីទ្វេភាគីរវាងតំណាងអង្គការអន្តរជាតិខាងការងារ (ILO) និងថ្នាក់ដឹកនាំមន្ត្រីជំនាញនៃ ប.ស.ស. សរុបប្រមាណជាង ១០រូប៕










# ឯកឧត្តមអគ្គនាយក ប.ស.ស.÷ ដើម្បីឲ្យការដាក់ដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ មន្ត្រី និងបុគ្គលិក ប.ស.ស. ទាំងអស់ត្រូវពង្រឹងសមត្ថភាព របស់ខ្លួន

ក្នុងឱកាសអញ្ជើញជាអធិបតីភាពបើកវគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន និងបច្ចុប្បន្នភាពការងារជំនាញនាព្រឹកនេះ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បានថ្លែងថា៖ ក្នុងរយៈពេលជាង១០ឆ្នាំកន្លងមក ប.ស.ស. បានអនុវត្តប្រកបដោយជោគជ័យរួចទៅហើយនូវរបបសន្តិសុខសង្គមចំនួន២ គឺ (១) របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និង (២) របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ហើយក្នុងពេលឆាប់ៗខាងមុខនេះ ប.ស.ស. នឹងចាប់ផ្តើមដាក់ដំណើរការ របបសន្តិសុខសង្គមថ្មីមួយទៀត គឺរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន។

**ឯកឧត្តមប្រតិភូ** បានថ្លែងបន្តថា៖ ដើម្បីឲ្យការដាក់ដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនថ្មីនេះ ប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ មន្ត្រី និងបុគ្គលិក ប.ស.ស. ដែលទទួលបន្ទុកលើកិច្ចការងារនេះ ត្រូវពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែមទៀត ធ្វើយ៉ាងណា








ផ្សព្វផ្សាយឲ្យបានកាន់តែទូលំទូលាយទៅកាន់សមាជិករបស់ខ្លួន ដើម្បីឲ្យពួកគាត់បានយល់ដឹងកាន់តែស៊ីជម្រៅ ក៏ដូចជាអត្ថប្រយោជន៍ដែលពួកគាត់ត្រូវទទួលបាននៅក្នុងរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន។

ថ្លែងក្នុងពិធីបើកវគ្គបណ្តុះបណ្តាលខាងលើនេះដដែល **ឯកឧត្តមប្រធាន** បានថ្លែងថា៖ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទើបធ្វើឲ្យប្រទេសជាតិបន្តមានសុខសន្តិភាព សេរីភាព និងការអភិវឌ្ឍពេញបរិបូណ៌ ហើយប្រការដែលកាន់តែគួរឲ្យកត់សម្គាល់ទៀតនោះ គឺការដាក់ចេញនូវគោលនយោបាយជាតិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ បានត្រឹមត្រូវ និងចំគោលដៅ រហូតឈានទៅដល់ការបើកដំណើរការប្រទេសឡើងវិញតាមបែបប្រក្រតីភាពថ្មី ដែលកត្តាទាំងនេះគឺជាការជំរុញ និងគាំទ្រ ប.ស.ស. ក្នុងនាម ជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គមនៅកម្ពុជា ឲ្យបន្តប្រឹងប្រែងបម្រើសេវាជូនបងប្អូនកម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធ ស្របតាមគោលនយោបាយជាតិគាំពារសង្គមរបស់រាជរដ្ឋាភិបាល។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធន គឺរបបសន្តិសុខសង្គមថ្មីមួយដែលផ្តល់ជាប្រាក់ចូលនិវិត្តន៍ (ប្រាក់រ៉ឺត្រែត) ជារៀងរាល់ខែ ជូនដល់សមាជិក ប.ស.ស. ដែលបានចុះបញ្ជីក្នុងផ្នែកនេះនៅពេលចូលនិវត្តន៍ធ្វើការលែងកើតចាប់ពីអាយុ ៦០ឆ្នាំឡើងទៅ។របបសន្តិសុខសង្គមផ្នែកប្រាក់សោធនត្រូវបានបែងចែកចេញជាបីប្រភេទ៖

១. ប្រាក់សោធនជរាភាព (ប្រាក់ចូលនិវិត្តន៍ (ប្រាក់រ៉ឺត្រែត)

២. ប្រាក់សោធនឧត្តរជីវី (ប្តី ឬប្រពន្ធ និងកូនក្នុងបន្ទុក)

៣.ប្រាក់សោធនទុព្វលភាព (ចូលនិវត្តន៍មុនកាលកំណត់)។






សូមបញ្ជាក់ថា៖ វគ្គបណ្ដុះបណ្ដាលខាងលើនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការកសាង និងលើកកម្ពស់សមត្ថភាពការយល់ដឹងបន្ថែមរបស់ថ្នាក់ដឹកនាំ មន្ត្រីបុគ្គលិកជំនាញ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការអនុវត្តការងាររបស់ខ្លួន ដើម្បីឆ្ពោះទៅរកឧត្តមភាព និងភាពចំុច្រើងជាលំដាប់ចំពោះការផ្ដល់សេវារបបសន្តិសុខសង្គមជូនសមាជិក ប.ស.ស.។

វគ្គបណ្ដុះបណ្ដាលនេះមានរយៈពេលចំនួន ៣ថ្ងៃ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២១ ខែកុម្ភៈ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ នៅសាលប្រជុំធំ ប.ស.ស. ស្នាក់ការកណ្ដាលរាជធានីភ្នំពេញ ដោយមានការចូលរួមពីថ្នាក់ដឹកនាំមន្ត្រី និងបុគ្គលិកជំនាញមកពីគ្រប់នាយកដ្ឋានជំនាញនៃ ប.ស.ស. ព្រមទាំងមានវត្តមានចូលរួមពី លោក លោកស្រី ជាថ្នាក់ដឹកនាំនៃ ប.ស.ស. សាខាខេត្ត-ខណ្ឌទាំង២៨ សរុបប្រមាណជាង ១០០នាក់ តាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting)៕









# ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ទទួលជួបពិភាក្សាការងារជាមួយប្រធានអង្គភាពសិទ្ធិសេដ្ឋកិច្ច និងសង្គម នៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំនៅកម្ពុជា

នេះជាជំនួបទ្វេភាគីលើកដំបូង ហើយដែល **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. បានទទួលជួបពិភាក្សា ជាមួយ **លោក ប៉ុកពង្ស ឡាវ៉ាន់ស៊ីរ** ប្រធានអង្គភាពសិទ្ធិសេដ្ឋកិច្ច និងសង្គម នៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំនៅកម្ពុជា ដើម្បីកំណត់វិធីសាស្ត្រ និងការអនុវត្តសកម្មភាពនានា ដែលអាចគាំទ្រឲ្យកាន់តែប្រសើរឡើងពាក់ព័ន្ធនឹងវិស័យសន្តិសុខសង្គមកម្ពុជា។

ក្នុងឱកាសជំនួបពិភាក្សានេះ **ឯកឧត្តមអគ្គនាយក** ប.ស.ស. បានសំដែងនូវការស្វាគមន៍ និងអំណរគុណចំពោះអង្គការសហប្រជាជាតិដែលបានរក្សាទុកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំនៅកម្ពុជា និងបានសហការគាំទ្រឲ្យកាន់តែប្រសើរឡើងពាក់ព័ន្ធនឹងវិស័យសន្តិសុខសង្គមកម្ពុជា ដើម្បីពង្រឹងនូវការអភិវឌ្ឍវិស័យសន្តិសុខសង្គម ដែលជាវិស័យដ៏សំខាន់មួយក្នុងការធានាបាននូវការគាំពារសន្តិសុខប្រាក់ចំណូលដល់សមាជិក ប.ស.ស. ដែលបណ្តាលមកពីការឈឺ គ្រោះថ្នាក់ការងារ ពិការភាព មាតុភាព និងចាស់ជរាជាដើម។










**ឯកឧត្តមអគ្គនាយក** ប.ស.ស. បានថ្លែងបញ្ជាក់បន្ថែមថា៖ កន្លងមក ថ្នាក់ដឹកនាំ ប.ស.ស. បានខិតខំបង្កើនកិច្ចសហការជាមួយអង្គការជាតិ និង អង្គការអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ជាច្រើន ក្នុងន័យដើម្បីពង្រឹង និងពង្រីកសមត្ថភាពការងារក្នុងការអនុវត្តទៅលើរបបសន្តិសុខសង្គមបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ចេញក្នុងន័យសំដៅជំរុញអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឲ្យកាន់តែរឹងមាំ និងល្អប្រសើរឡើងព្រមទាំងអាចគ្របដណ្តប់ទៅដល់ប្រជាជនគ្រប់រូប ប្រកបដោយបរិយាប័ន្ន ប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ ដែលជាឧបករណ៍បម្រើដល់ការកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ហើយរួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សកាន់តែទូលំទូលាយ និងជំរុញកំណើនសេដ្ឋកិច្ច។







ជាមួយគ្នានេះ **លោក ប៉ុកពន្យ ឡាវ៉ាន់ស៊ីរ៉ី** ក៏បានលើកឡើងផងដែរថា៖ ក្នុងនាមជាប្រធានអង្គភាពសិទ្ធិសេដ្ឋកិច្ច និងសង្គម នៃការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិ-មនុស្ស (OHCHR) ប្រចាំនៅកម្ពុជា លោកនឹងបង្កើនកិច្ចសហការការងារដ៏ល្អជាមួយ ប.ស.ស. ដើម្បីសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សពាក់ព័ន្ធនឹងការលើកកម្ពស់ និងការការពារសិទ្ធិសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ជាពិសេសទទួលបានរបបសន្តិសុខសង្គម និងសិទ្ធិទទួលបានជីវភាពសមរម្យ។

សូមបញ្ជាក់ជូនថា៖ ជំនួបពិភាក្សាទ្វេភាគីខាងលើនេះ ប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ទី១០ ខែមីនា ឆ្នាំ២០២២ នៅសាលប្រជុំធំ ស្នាក់ការកណ្ដាល រាជ-ធានីភ្នំពេញ ដោយមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ ប.ស.ស. ព្រមទាំងថ្នាក់ដឹកនាំនៃអង្គភាពសេដ្ឋកិច្ច និងសង្គមនៃការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំនៅកម្ពុជា សរុបចំនួន ១១រូប៕












# ការដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់ គឺជាគន្លឹះស្នូល ដែលថ្នាក់ដឹកនាំនាយកដ្ឋាន និងប្រធានសាខា ប.ស.ស. ខេត្ត-ខណ្ឌ ទាំងអស់ត្រូវបន្តដោះស្រាយឲ្យបានទាន់ពេលវេលា

ថ្លែងក្នុងឱកាសអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំពិនិត្យលើវឌ្ឍនភាពការងារសម្រេចបាន ព្រមទាំងដោះស្រាយបញ្ហាប្រឈមផ្សេងៗប្រចាំខែកុម្ភៈ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. បានលើកឡើងថា ៖ ការដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់ គឺជាគន្លឹះស្នូល ដែលថ្នាក់ដឹកនាំនាយកដ្ឋាន និងប្រធានសាខា ប.ស.ស. ខេត្ត-ខណ្ឌ ទាំងអស់ ត្រូវបន្តដោះស្រាយឲ្យបានទាន់ពេលវេលាជាមួយគ្នា ប្រកបដោយភាពទន់ភ្លន់ ម៉ឺងមាត់ ក្នុងការបំពេញកិច្ចការ ដោយធ្វើយ៉ាងណាឲ្យការអនុវត្តការងារ កាន់តែមានប្រសិទ្ធភាព ទទួលបាននូវលទ្ធផលខ្ពស់ បើទោះបីកន្លងមកថ្នាក់ដឹកនាំមន្ត្រី បុគ្គលិកទាំងអស់បានបំពេញកិច្ចការងារ ក្នុងការបម្រើសេវាជូនសមាជិក ប.ស.ស. បានល្អប្រសើរគួរឲ្យកត់សំគាល់យ៉ាងណាក៏ដោយ។







**ឯកឧត្តមអគ្គនាយក** ប.ស.ស. បានថ្លែងសង្កត់ធ្ងន់ថា ការសម្រេចបាននូវលទ្ធផលដ៏ប្រសើរនេះ យើងក៏មិនភ្លេចពីការដឹងគុណបំផុតចំពោះការដឹកនាំប្រទេសដែលមានគតិបណ្ឌិត និងឈ្លាសវៃខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដែលសម្តេចបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ពិសេសតាមរយៈនូវគោលនយោបាយចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋ ដែលនេះជាយុទ្ធសាស្ត្រគន្លឹះដ៏សំខាន់បំផុត ក្នុងការបង្កើតឲ្យបាននូវភាពស៊ាំសហគមន៍ ដែលអាចទប់ទល់នឹងមេរោគកូវីដ-១៩ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាជន រហូតគ្រប់គ្រងស្ថានភាពនៃការរីករាលដាលនៃជំងឺឆ្លងដ៏សាហាវនេះ និងបានដំណើរការប្រទេសជាតិពេញលេញឡើងវិញលើគ្រប់វិស័យ ហើយត្រូវបន្តរស់នៅតាមគន្លងប្រក្រតីថ្មី ដោយត្រូវគោរព និងអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវវិធានសុខាភិបាល ៣ការពារ និង ៣កុំ ក្រោមការដាក់ចេញពីសំណាក់ប្រមុខដឹកនាំ នៃរាជរដ្ឋាភិបាលកម្ពុជា។

**ឯកឧត្តមអគ្គនាយក** ប.ស.ស. ក៏បានជំរុញលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ លោក លោកស្រីជា ប្រធាន អនុប្រធាន និងមន្ត្រី បុគ្គលិក ប.ស.ស. គ្រប់សាខាទាំងអស់ត្រូវបន្តពន្លឿនការដោះស្រាយបញ្ហាប្រឈមផ្សេងៗដែលជាឧបសគ្គក្នុងការអនុវត្តការងារ ពិសេសសម្របសម្រួលចំពោះបងប្អូនដែលជាសមាជិក ប.ស.ស. ពេលទៅទទួលសេវានៅតាមមូលដ្ឋានសុខាភិបាលដែលជាដៃគូ ប.ស.ស. ក៏ដូចជាពេលមកទទួលសេវាក្នុងការស្នើសុំប្រាក់ឧបត្ថម្ភផ្សេងៗ ពី ប.ស.ស. ឲ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំខាងលើប្រព្រឹត្តទៅនាព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ នៅសាលប្រជុំធំស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ ព្រមទាំងលោក លោកស្រី ដែលជាប្រធាន អនុប្រធាន សាខា ប.ស.ស. ខេត្ត-ខណ្ឌ សរុបប្រមាណជាង ១០០នាក់ ទាំងដោយផ្ទាល់ និងតាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting)៕









# អ្នកបើកបរយានយន្តដឹកកម្មករ និងបងប្អូនកម្មករនិយោជិត ប្រមាណជិត ២០០នាក់ បានចូលរួមឈ្វេងយល់ច្បាប់ ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក

ស្របពេលដែលស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានការថមថយ និងបានបើកដំណើរការឡើងវិញគ្រប់វិស័យ នាថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បានចុះប្រជុំផ្សព្វផ្សាយអប់រំច្បាប់ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើកដំបូងរបស់ខ្លួន ជូនដល់អ្នកបើកបររថយន្តដឹកកម្មករ និងបងប្អូនកម្មករនិយោជិត សរុបប្រមាណជិត ២០០នាក់ នៅរោងចក្រ CAMBO UNISOLL CO.,LTD ស្ថិតនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ក្នុងន័យបញ្ជ្រាបការយល់ដឹងបន្ថែមអំពីច្បាប់ចរាចរណ៍ផ្លូវគោក នៅពេលធ្វើដំណើរលើដងផ្លូវ។

**ឯកឧត្តម ហេង សុផាន់ណារិទ្ធ** អគ្គនាយករង នៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ជាសមាជិកគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃ ប.ស.ស. ក្នុងឱកាស**ឯកឧត្តម**អញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំផ្សព្វផ្សាយខាងលើ **ឯកឧត្តម** បានថ្លែងឲ្យដឹងថា៖ ករណីគ្រោះថ្នាក់ចរាចរណ៍ នៅតែបន្តកើតមានឡើងលើបងប្អូនកម្មករនិយោជិត នៅពេលធ្វើដំណើរ ឬដោយមធ្យោបាយផ្សេងៗ ក្នុងនោះរថយន្តដឹកកម្មករនិយោជិតមួយចំនួន ត្រូវបានកែច្នៃចេញពីរថយន្តដឹកទំនិញទៅជារថយន្តដឹកកម្មករ ជាហេតុធ្វើឲ្យមិនស្របទៅតាមលក្ខណៈបច្ចេកទេសយានយន្ត។





**ឯកឧត្តមអគ្គនាយករង** បានធ្វើការសំណូមពរដល់ បងប្អូនកម្មករនិយោជិតទាំងអស់ ជាពិសេសអ្នកបើកបររថយន្តដឹកកម្មករ ត្រូវចូលរួមគោរពច្បាប់ចរាចរណ៍ឲ្យបានគ្រប់ៗ និងចេះយោគយល់អធ្យាស្រ័យ នៅពេលធ្វើដំណើរនៅតាមដងផ្លូវ ពិសេសត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ ១០ចំណុចដូចខាងក្រោម៖

១. មិនត្រូវបើកបរលើសល្បឿនកំណត់ដាច់ខាត

២. មិនត្រូវបើកបរស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងដាច់ខាត

៣. មិនត្រូវបើកបរស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀនដាច់ខាត

៤. មិនត្រូវបើកបរស្ថិតក្រោមស្ថានភាពងងុយដេកដាច់ខាត

៥. ត្រូវពាក់មួកសុវត្ថិភាពជានិច្ច

៦. ត្រូវពាក់ខ្សែក្រវ៉ាត់សុវត្ថិភាពជានិច្ច

៧. ត្រូវប្រកាន់ស្តាំជានិច្ច

៨. ត្រូវត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តជានិច្ច

៩. ត្រូវចេះបើកបរឲ្យបានត្រឹមត្រូវជាដាច់ខាត

១០. ត្រូវប្រុងប្រយ័ត្នជានិច្ច។









**ឯកឧត្តម ព្រាប ចំនួនវិបុល** ទីប្រឹក្សាក្រសួងសាធារណៈការ និងដឹកជញ្ជូន និងជាអនុប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃ ប.ស.ស. ក្នុងឱកាសជាមួយគ្នានោះផងដែរ ឯកឧត្តមក៏បានអំពាវនាវដល់បងប្អូនអ្នកបើកបររថយន្តដឹកកម្មករទាំងអស់ ធ្វើយ៉ាងណាត្រូវ៖

- ចូលរួមគោរព និងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកឲ្យបានខ្ជាប់ខ្ជួន
- សម្រាប់ឡានដឹកកម្មករ មិនត្រូវផ្ទុកកម្មករលើសចំណុះដាច់ខាត
- ត្រួតពិនិត្យយានយន្តមុនពេលចេញទៅដឹកបងប្អូនកម្មករ - កម្មការិនី
- ត្រូវទៅឆៀករថយន្តជាប្រចាំ
- អ្នកបើកបររថយន្តដឹកកម្មករទាំងអស់ ត្រូវទៅប្រឡងយកប័ណ្ណបើកបរឲ្យស្របតាមប្រភេទយាន។

គួរបញ្ជាក់ឲ្យដឹងថា៖ នៅក្នុងឆ្នាំ ២០២១ កន្លងទៅមានករណីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក បានកើតឡើងលើបងប្អូនកម្មករនិយោជិតសរុបចំនួន ៣២៦៨ករណី ដែលមានជនរងគ្រោះសរុបចំនួន ៣៨៧៥នាក់ (ស្លាប់ ១០៩នាក់ របួសធ្ងន់ ៩០៥នាក់ និងរបួសស្រាល ២៨៦១នាក់) ក្នុងនោះគ្រោះថ្នាក់លើរថយន្តដឹកកម្មករនិយោជិត មានចំនួន ១១លើក និងមានជនរងគ្រោះសរុបចំនួន ៣៤៩នាក់ (ស្លាប់ ៣នាក់ របួសធ្ងន់ ៥០នាក់ និងរបួសស្រាល ២៩៦នាក់) នេះបើយោងតាមរបាយការណ៍របស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)។

សូមបញ្ជាក់ថា៖ ការប្រជុំផ្សព្វផ្សាយខាងលើ ប្រព្រឹត្តទៅនៅរោងចក្រ CAMBO UNISOLL CO.,LTD មានទីតាំងស្ថិតនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដោយមានវត្តមានចូលរួមពីតំណាងមន្ទីរស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ព្រមទាំងមានការចូលរួមពីបងប្អូនអ្នកបើកបររថយន្តដឹកកម្មករនិយោជិត និងកម្មករនិយោជិតសរុបប្រមាណជិត ២០០នាក់៕

-









# នាយកដ្ឋានគោលនយោបាយសន្តិសុខសង្គម នៃ ប.ស.ស. បើកកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងារសម្រេចបានប្រចាំខែរបស់ខ្លួន

នាយកដ្ឋានគោលនយោបាយសន្តិសុខសង្គម នៃ ប.ស.ស. នាថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ បានបើកកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងារសម្រេចបានប្រចាំខែរបស់ខ្លួន ដើម្បីពិនិត្យមើលនូវបញ្ហាប្រឈមនានា រួមទាំងដំណោះស្រាយក្នុងការអនុវត្តការងារឲ្យកាន់តែល្អប្រសើរ ប្រកបដោយប្រសិទ្ធភាព និងលទ្ធផលខ្ពស់ជូនអង្គភាពរបស់ខ្លួន។

ក្នុងឱកាសអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំខាងលើនេះ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. បានលើកឡើងថា កន្លងមក













ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក នៃនាយកដ្ឋានគោលនយោបាយសន្តិសុខសង្គម បានពុះពាររាល់ការលំបាកក្នុងការបំពេញការងារបម្រើស្ថាប័ន ក៏ដូចជាសមាជិក ប.ស.ស. រហូតសម្រេចបានលទ្ធផលល្អគួរឲ្យកត់សម្គាល់ ឆ្លើយតបទៅនឹងគោលនយោបាយជាតិគាំពារសង្គមដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា។

គួរឲ្យដឹងដែរថា៖ នាយកដ្ឋានគោលនយោបាយសន្តិសុខសង្គម នៃ ប.ស.ស. មានតួនាទីសំខាន់ក្នុងការរៀបចំចងក្រងនូវឯកសារច្បាប់ និងលិខិតបទដ្ឋាននានា ក៏ដូចជារៀបចំផែនការយុទ្ធសាស្ត្រការងាររបស់ស្ថាប័ន ប.ស.ស. ផងដែរ។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំខាងលើនេះ ប្រព្រឹត្តទៅនៅសាលប្រជុំធំនៃ ប.ស.ស. ស្នាក់ការកណ្តាលរាជធានីភ្នំពេញ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកនៃនាយកដ្ឋានគោលនយោបាយសន្តិសុខសង្គមសរុបប្រមាណជាង ៣០នាក់៕









# មន្ត្រី និងបុគ្គលិកនៃនាយកដ្ឋាន សេវាអតិថិជន និងទំនាក់ទំនងសាធារណៈនៅតែបន្តការលើកសរសើរ ពីថ្នាក់ដឹកនាំរបស់ខ្លួន

ជារៀងរាល់ខែ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តែងតែអញ្ជើញចូលរួមអធិបតីភាពក្នុងការដឹកនាំមន្ត្រី និងបុគ្គលិកនៃនាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ ប្រជុំត្រួតពិនិត្យមើលលទ្ធផលការងារ និងបញ្ហាប្រឈមនានាដែលនៅសេសសល់ ដើម្បីបន្តអនុវត្តការងាររបស់ខ្លួនឲ្យកាន់តែល្អប្រសើរឡើង។

**ឯកឧត្តមអគ្គនាយករង** បានថ្លែងថា៖ នាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈពិតជាមានតួនាទីសំខាន់ណាស់ ក្នុងការសម្របសម្រួលផ្តល់ព័ត៌មាន និងទទួលព័ត៌មានពីសមាជិក ប.ស.ស. ពីគ្រប់មជ្ឈដ្ឋាន រួមទាំងការស្រាវជ្រាវទាក់ទងនឹងវិស័យសន្តិសុខសង្គម ការផ្សព្វផ្សាយព័ត៌មាន ការធ្វើបទយកការណ៍ ការផលិតវីដេអូអប់រំ និងការរចនាខិតប័ណ្ណ













ផ្សេងៗជាច្រើនសម្រាប់ ប.ស.ស.។ ដូច្នេះ ក្នុងនាមថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក ដែលកំពុងបំពេញការងារក្នុងនាយកដ្ឋានមួយនេះ ត្រូវធ្វើយ៉ាងណាបន្តអនុវត្តសកម្មភាពការងាររបស់ខ្លួនឲ្យបានកាន់តែល្អប្រសើរបន្ថែមទៀត ក្នុងការបម្រើសេវាជូនបងប្អូនជាសមាជិក ប.ស.ស. ឲ្យទាន់ពេលវេលា និងប្រកបដោយគុណភាព។

ជាមួយនឹងការលើកឡើងខាងលើនេះដែរ **ឯកឧត្តមអគ្គនាយករង** ក៏បានបន្តជំរុញលើកទឹកចិត្ត និងបានពាំនាំនូវអនុសាសន៍ **ឯកឧត្តមប្រតិភូ**រាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. ដោយសង្កត់ធ្ងន់ថា៖ ក្នុងនាមជាអ្នកបម្រើសេវាជូនសមាជិករបស់ខ្លួន ថ្នាក់ដឹកនាំ មន្ត្រីទាំងអស់ គប្បីប្រកាន់ខ្ជាប់នូវក្រមសីលធម៌ល្អ ក្នុងការដឹកនាំអនុវត្តប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ ក្នុងការងារ និងត្រូវខិតខំបន្ថែមទៀតទៅលើការងារដែលសម្រេចបាន ធ្វើយ៉ាងណាឲ្យការអនុវត្តការងារកាន់តែមានប្រសិទ្ធភាព ទទួលបានលទ្ធផលខ្ពស់ និងត្រូវគោរពអនុវត្ត នូវវិធានសុខាភិបាល ក្រោមការដាក់ចេញ ពីសំណាក់ប្រមុខដឹកនាំ នៃរាជរដ្ឋាភិបាលកម្ពុជាពិសេសត្រូវអនុវត្តនូវវិធាន ៣ការពារ និង ៣កុំ ឲ្យបានជាប់ជានិច្ច ក្នុងន័យរួមចំណែកទប់ស្កាត់ នៃការឆ្លងរីករាលដាលជំងឺកូវីដ-១៩។

ទន្ទឹមគ្នានេះ **ឯកឧត្តមអគ្គនាយករង** បានលើកទឹកចិត្ត និងកោតសរសើរ ចំពោះការខិតខំប្រឹងប្រែងបំពេញការងារពីថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក របស់នាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ ដែលកន្លងមកនេះសម្រេចបានលទ្ធផលល្អ គួរជាទីគាប់ប្រសើរ បើទោះបីជានៅមានចំណុចប្រឈមខ្លះៗ ត្រូវកែលំអរធ្វើយ៉ាងណាឲ្យកាន់តែមានលក្ខណៈល្អបំផុតឆ្លើយតបទៅនឹងគោលនយោបាយជាតិគាំពារសង្គម បានដាក់ចេញដោយរាជរដ្ឋាភិបាលដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុត នៃកម្ពុជា។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំខាងលើប្រព្រឹត្តទៅនាថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ នៅសាលប្រជុំធំនៃ ប.ស.ស. ស្នាក់ការកណ្តាលរាជធានីភ្នំពេញ ដោយមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកនៃនាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈសរុបប្រមាណជាង ៣០នាក់៕






# ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស ប.ស.ស. ចូលរួមកិច្ចប្រជុំពិភាក្សា ផ្លាស់ប្តូរមតិយោបល់ ជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី

ដោយទទួលបានការអនុញ្ញាតពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នាថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២២ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. បានដឹកនាំមន្ត្រីបច្ចេកទេសចូលរួមក្នុងកិច្ចប្រជុំពិភាក្សា ដើម្បីផ្លាស់ប្តូរមតិយោបល់ និងសកម្មភាពផ្សេងៗ ជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងការប្រមូលជាធាតុចូលសំខាន់ៗ ដើម្បីអាចដាក់បញ្ចូលទៅក្នុងគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំនៅកម្ពុជាដែលនឹងគ្រោងអនុវត្ត។

ចំណុចសំខាន់ៗចំនួន៤ ត្រូវបានលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំដែលរួមមាន (១) ត្រួតពិនិត្យអំពីវឌ្ឍនភាពនៃការរៀបចំគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) (២) ត្រួតពិនិត្យអំពីធាតុចូលនៃហិរញ្ញប្បទានសុខាភិបាល នៃកិច្ចសហប្រតិបត្តិការទៅលើវិស័យសន្តិសុខសង្គម ដើម្បីដាក់បញ្ចូលក្នុងគម្រោងសុខភាពតាមព្រំដែនមហាអនុតំបន់ទន្លេមេគង្គសម្រាប់សុខភាពជនទេសន្តរប្រវេសន៍ (៣) ពិភាក្សាផ្លាស់ប្តូរយោបល់ អំពីផែនការសកម្មភាពដែលអាចដាក់បញ្ចូលក្នុងការរៀបចំគម្រោងខាងលើ ដើម្បីលើកកម្ពស់ការចុះឈ្មោះកម្មករនិយោជិតក្នុងប្រព័ន្ធ ជាពិសេស ផ្តោតទៅលើតំបន់សេដ្ឋកិច្ចពិសេសខេត្តបន្ទាយមានជ័យ និង (៤) ពិភាក្សាអំពីជំហានបន្ទាប់ និងការងារផ្សេងៗ។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំខាងលើនេះ ប្រព្រឹត្តទៅតាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting) នៅសាលប្រជុំធំ ប.ស.ស. ដោយមានការចូលរួមពីទ្វេភាគីរវាង ប.ស.ស. និងតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សរុបប្រមាណជាង ១០រូប។








# តំណាង ប.ស.ស. កម្ពុជា ចូលរួមក្នុងវេទិកាស្តីពី “សន្តិសុខសង្គមប្រចាំនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិកសម្រាប់ឆ្នាំ២០២២” របស់សមាគមសន្តិសុខសង្គមអន្តរជាតិ (International Social Security Association, ISSA)

នាថ្ងៃអង្គារ ទី២២ ខែកុម្ភៈ ឆ្នាំ២០២២ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បានដឹកនាំមន្ត្រី និងបុគ្គលិក ប.ស.ស. ចូលរួមក្នុងវេទិកាស្តីពី "សន្តិសុខសង្គមប្រចាំនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិកសម្រាប់ឆ្នាំ២០២២" របស់សមាគមសន្តិសុខសង្គមអន្តរជាតិ (ISSA) តាមរយៈប្រព័ន្ធអនឡាញ ស្របពេលដែល ប.ស.ស. កម្ពុជា ត្រៀមចូលជាសមាជិកនៃសមាគមសន្តិសុខសង្គមអន្តរជាតិ (ISSA)។

តាមការបញ្ជាក់ពីសំណាក់ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** បានឲ្យដឹងថា៖ វេទិកាដ៏មានសារៈសំខាន់ខាងលើនេះ ផ្តោតសំខាន់ទៅលើកិច្ចពិភាក្សាលម្អិតអំពីគន្លឹះជាអាទិភាព និងការរំពឹងទុកសម្រាប់ការពង្រីកការគ្របដណ្តប់សន្តិសុខសង្គម ហិរញ្ញវត្ថុ តាវកាលិក និងសេវា និងការវិភាគអំពីផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែងនៃការរីករាលដាលជំងឺកូវីដ-១៩។











**ឯកឧត្តមអគ្គនាយករង** បានថ្លែងឲ្យដឹងទៀតថា៖ ក្នុងវេទិកាខាងលើក៏បានពិភាក្សាដោយសង្កត់ធ្ងន់ផងដែរទៅលើ៖ (១) សន្តិសុខសង្គមក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិករួមមាន៖ វឌ្ឍនភាព - បញ្ហាប្រឈម និងដំណោះស្រាយ (២) នវានុវត្តន៍នៅក្នុងការគ្រប់គ្រងរបបសន្តិសុខសង្គម និង (៣) យុទ្ធសាស្ត្រសម្រាប់បំពេញតម្រូវការសន្តិសុខសង្គមនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

សូមបញ្ជាក់ថា៖ វេទិកាខាងលើនេះរៀបចំឡើងដោយសមាគមសន្តិសុខសង្គមអន្តរជាតិ (ISSA) ដែលមានរយៈពេល ៣ថ្ងៃ ចាប់ពីថ្ងៃទី២២-២៤ ខែកុម្ភៈ ឆ្នាំ-២០២២ ដោយមានការចូលរួមពីតំណាងស្ថាប័នសន្តិសុខសង្គមជាសមាជិក នៃសមាគមសន្តិសុខសង្គមអន្តរជាតិ (ISSA) ជាង៣២០ស្ថាប័ន ក្នុងចំណោមប្រមាណ ១៦០ប្រទេសផ្សេងគ្នា៕











# មន្ត្រីជំនាញ ប.ស.ស. ជាច្រើនរូបចូលរួមកិច្ចប្រជុំស្តីពី “គម្រោងពហុវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅប្រទេសកម្ពុជា (MUSEFO)” របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ

នាថ្ងៃពុធ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ **ឯកឧត្តម ប៉ែន នរៈឧុធ** អគ្គនាយករង ប.ស.ស. និងជាសមាជិករបស់ក្រុមការងារបង្កើនអាហារូបត្ថម្ភនៅកម្ពុជាបានដឹកនាំមន្ត្រី និងបុគ្គលិក ប.ស.ស. ជាច្រើនរូបចូលរួមក្នុងកិច្ចប្រជុំស្តីពី“គម្រោងពហុវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅប្រទេសកម្ពុជា(MUSEFO)” ក្រោមប្រធានបទ ពិភពលោកតែមួយគ្មានភាពអត់ឃ្លាន របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ (ក.ក.ជ) តាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting)។

កិច្ចប្រជុំនេះ បានពិភាក្សា និងផ្តោតទៅលើចំណុចសំខាន់ៗរួមមាន៖ (១) ពិនិត្យផែនការយុទ្ធសាស្ត្ររបស់គម្រោងពហុវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា (២) ពិនិត្យលើរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០២១ និងបញ្ហាប្រឈម និង (៣) រៀបចំផែនការសកម្មភាពការងាររបស់គម្រោងពហុវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជាសម្រាប់ឆ្នាំ២០២២ និងស្វែងរកការគាំទ្រ និងអនុសាសន៍សម្រាប់អនុវត្តបន្តពីក្រសួងស្ថាប័ននានា។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំខាងលើនេះ រៀបចំឡើងដោយក្រុមប្រឹក្សាស្តារ-អភិវឌ្ឍវិស័យកសិកម្ម និងជនបទ (ក.ក.ជ) ដោយមានការចូលរួមពីតំណាងក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាសរុបជាង ១០ស្ថាប័ន៕












# វគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន និងបច្ចុប្បន្នភាពការងារជំនាញ

រយៈពេល៣ថ្ងៃពេញ ប.ស.ស. បានរៀបចំវគ្គបណ្តុះបណ្តាលនេះឡើង សម្រាប់ពង្រឹងសមត្ថភាពបន្ថែមដល់មន្ត្រី និងបុគ្គលិកជំនាញរបស់ខ្លួនស្តីពី "របបសន្តិសុខសង្គមផ្នែកប្រាក់សោធន" មុនពេលដាក់ឲ្យដំណើរការ។

តាមរយៈវគ្គបណ្តុះបណ្តាលដ៏មានសារៈសំខាន់ប៉ុន្មានថ្ងៃនេះ សិក្ខាកាមជាថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកជំនាញ នៃ ប.ស.ស. ទទួលបានចំណេះដឹងកាន់តែច្បាស់ និងកាន់តែស៊ីជម្រៅស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនថ្មីនេះ ព្រមទាំងទទួលបាននូវបទពិសោធន៍ល្អៗរវាងគ្នា សម្រាប់យកទៅអនុវត្តលើការងាររបស់ខ្លួន ក្នុងការបម្រើសេវាជូនសមាជិកប្រកបដោយគុណភាព ស័ក្តិសិទ្ធិភាព និងទាន់ពេលវេលា។

**ឯកឧត្តម ម៉េង ហុង** អគ្គនាយករង ប.ស.ស. តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ក្នុងឱកាសអញ្ជើញបិទវគ្គបណ្តុះបណ្តាល នាថ្ងៃពុធ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ **ឯកឧត្តម** បានសម្តែងការកោតសរសើរយ៉ាងខ្លាំង ចំពោះលោក លោកស្រី ជាថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងបុគ្គលិកនៃ ប.ស.ស. ទាំងអស់ដែលបានយកចិត្តទុកដាក់ចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពី "របបសន្តិសុខសង្គមផ្នែកប្រាក់សោធន និងបច្ចុប្បន្នភាពការងារជំនាញ រយៈពេល ៣ថ្ងៃកន្លងមកនេះ។

**ឯកឧត្តមអគ្គនាយករង** បានបន្តទៀតថា ទោះបីជាវគ្គបណ្តុះបណ្តាលនេះរៀបចំឡើយតាមរយៈប្រព័ន្ធវីដេអូ(Zoom) យ៉ាងណាក៏ដោយ តែអស់លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក ប.ស.ស. ទាំងអស់បានយកចិត្តទុកដាក់ខ្ពស់ក្នុងការចូលរួមយ៉ាងផុលផុស តាមរយៈការលើកឡើងជាសំណួរ និងការចូលរួមយ៉ាងសកម្មក្នុងវគ្គបណ្តុះបណ្តាលនេះ។

ក្នុងឱកាសនោះដែរ **ឯកឧត្តម** បានវាយតម្លៃខ្ពស់ ចំពោះការយកចិត្តទុកដាក់ខិតខំរៀនសូត្រ និងបានផ្តាំផ្ញើរដល់សិក្ខាកាមជាថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកនៃ ប.ស.ស. ទាំងអស់ សូមយកចំណេះដឹងពីការរៀនសូត្រអស់រយៈពេល ៣ថ្ងៃនេះ ទៅបំពេញការងាររបស់ខ្លួនឲ្យកាន់តែល្អប្រសើរថែមទៀត និងសូមបន្តចូលរួមពង្រឹងវិន័យ សាមគ្គីភាពផ្ទៃក្នុងការអនុវត្តការងារប្រកបដោយការយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ ជាពិសេស ត្រូវបន្តអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវវិធានការ ៣កុំ និង ៣ការពារ។

សូមបញ្ជាក់ថា៖ វគ្គបណ្តុះបណ្តាលនេះមានរយៈពេលចំនួន ៣ថ្ងៃ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២១ ខែកុម្ភៈ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ នៅសាលប្រជុំធំ ប.ស.ស. ស្នាក់ការកណ្តាលរាជធានីភ្នំពេញ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកជំនាញមកពីគ្រប់នាយកដ្ឋានជំនាញនៃ ប.ស.ស. ព្រមទាំងមានវត្តមានចូលរួមពី លោក លោកស្រី ជាថ្នាក់ដឹកនាំនៃ ប.ស.ស. សាខាខេត្ត-ខណ្ឌទាំង២៨ សរុបប្រមាណជាង ១០០នាក់ តាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting)៕



# មន្ត្រីជំនាញនៃ ប.ស.ស. ជួបប្រជុំពិភាក្សាជាមួយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) ទាក់ទងលើការសិក្សាសមិទ្ធិលទ្ធភាពនៃកិច្ចសហប្រតិបត្តិការ

ក្នុងកិច្ចប្រជុំពិភាក្សាគ្នានេះ ផ្តោតសំខាន់ទៅលើការឈ្វេងយល់ពីតម្រូវការរបស់ ប.ស.ស. ជាពិសេសទៅលើការកសាងសមត្ថភាព មន្ត្រី និងបុគ្គលិក ប.ស.ស.។កិច្ចប្រជុំនាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២ ប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៅសាលប្រជុំធំ ប.ស.ស. ស្នាក់ការកណ្តាលរាជធានីភ្នំពេញ តាមរយៈប្រព័ន្ធវីដេអូ (Zoom - Meeting)។

តាមរយៈកិច្ចប្រជុំនេះ **ឯកឧត្តមអគ្គនាយករង** បានសម្តែងនូវសេចក្តីរីករាយនិងចាប់អារម្មណ៍ជាខ្លាំងចំពោះកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) ទៅលើការអភិវឌ្ឍ ប.ស.ស. ក្នុងការបម្រើសមាជិកសម្រាប់វិស័យសន្តិសុខសង្គមប្រកបដោយនិរន្តរភាព តាមរយៈការផ្តល់ជំនួយនានា ការពង្រីកវិសាលភាពនៃការគ្របដណ្តប់របបសន្តិសុខសង្គមទៅលើវិស័យមួយចំនួនបន្ថែមទៀត ដូចជា៖ បុគ្គលស្វ័យនិយោជន៍ (Self-employed) វិស័យសំណង់ (Construction sector) និងវិស័យកសិកម្ម (Agricultural sector)។








គួររំលឹកផងដែរថា ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) ប្រចាំនៅកម្ពុជាកន្លងមកក៏ធ្លាប់បានផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុតាមរយៈអង្គការហ្រ្គេត (GRET) ជូន ប.ស.ស. ក្នុងការអនុវត្តគម្រោងសាកល្បង ស្តីពីកិច្ចគាំពារសង្គមផ្នែកនវានុវត្តន៍សម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (SPIN-Project) ផងដែរ ដែលក្នុងនោះរួមមាន (១) ការអភិវឌ្ឍមជ្ឈមណ្ឌលព័ត៌មាននៃ ប.ស.ស. (NSSF Call Center Development) (២) ការអភិវឌ្ឍកម្មវិធីតាមគេហទំព័រ (Web Application Development) សម្រាប់ការចុះបញ្ជិកា និងបង់ភាគទានរបស់កម្មករនិយោជិតនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (អ្នកបើកម៉ូតូរ៉ឺម៉ក និងអ្នកបម្រើក្នុងផ្ទះ) (៣) ការវាយតម្លៃហិរញ្ញវត្ថុ (Financial Assessment) និង (៤) យុទ្ធសាស្ត្រ នៃការផ្សព្វផ្សាយ (Communication Strategy) សម្រាប់គម្រោង SPIN៕












# ជាង ៣២០ស្ថាប័ន ដែលមកពី ១៦០ប្រទេស ផ្សេងៗគ្នា ចូលរួមក្នុងសិក្ខាសាលាដ៏សំខាន់មួយ តាមរយៈប្រព័ន្ធអនឡាញ ដែលក្នុងនោះ ក៏មាន ប.ស.ស. កម្ពុជា ផងដែរ

នាល្ងាចថ្ងៃព្រហស្បតិ៍ ទី១០ ខែមីនា ឆ្នាំ២០២២ ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីបច្ចេកទេស តំណាងឲ្យបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) កម្ពុជា ក្នុងនាមស្ថាប័នដែលត្រៀមចូលជាសមាជិក នៃសមាគមសន្តិសុខសង្គមអន្តរជាតិ (International Social Security Association, ISSA) ដឹកនាំដោយ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ឹក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បាន ចូលរួមសិក្ខាសាលាដ៏មានសារៈសំខាន់មួយ ស្តីពី "ការពង្រីកកិច្ចគាំពារសង្គមសម្រាប់ពលករទេសន្តរប្រវេសក៍ ជនភៀសខ្លួន និងសមាជិកគ្រួសារ៖ ការណែនាំសម្រាប់អ្នកបង្កើតគោលនយោបាយ និងអ្នកអនុវត្តន៍" តាមរយៈប្រព័ន្ធអនឡាញ។



តាមការបញ្ជាក់ពីសំណាក់ **ឯកឧត្តម-អគ្គនាយករង** ប.ស.ស. បានឲ្យដឹងថា៖ សិក្ខាសាលាខាងលើនេះ បានពិភាក្សា-ដោយផ្តោតលើចំណុចសំខាន់ៗ មួយចំនួនរួមមាន (១) ដំណោះស្រាយ បញ្ហាប្រឈមដល់ពលកររទេសន្តរប្រវេសក៍ក្នុងការទទួលបានកិច្ចគាំពារសង្គមនៅក្នុងប្រទេសទទួល និងនៅពេលត្រឡប់ទៅប្រទេសកំណើតរបស់ខ្លួនវិញ (២) ការបង្ហាញអំពីវិធីសាស្រ្តផ្សេងៗ ក្នុងការពង្រីកកិច្ចគាំពារសង្គមដល់ពលកររទេសន្តរប្រវេសក៍ និងសមាជិកគ្រួសារ (៣) ការពិភាក្សាអំពីជម្រើស-គោលនយោបាយ ដែលបានបង្ហាញនៅក្នុងការណែនាំ ដោយផ្អែកលើបទពិសោធន៍ និងការអនុវត្តថ្នាក់ជាតិ និង (៤) ការបង្ហាញអំពីទស្សនៈរបស់តំណាងកម្មករនិយោជិត និងនិយោជកលើខ្លឹមសារនៃការណែនាំ និងជម្រើសគោលនយោបាយ។

សូមបញ្ជាក់ថា៖ សិក្ខាសាលាខាងលើនេះ រៀបចំឡើងដោយសមាគមសន្តិ-សុខសង្គមអន្តរជាតិ (ISSA) ដោយមានការចូលរួមពីតំណាងស្ថាប័នសន្តិសុខសង្គមជាសមាជិក នៃសមាគមសន្តិសុខសង្គមអន្តរជាតិ (ISSA) ជាង ៣២០-ស្ថាប័ន ដែលមកពី ១៦០ប្រទេសផ្សេងៗគ្នា ព្រមទាំងមានការចូលពីសមាសភាពត្រីភាគីរបស់អង្គការអន្តរជាតិខាងការងារ (ILO) ទីភ្នាក់ងារដៃគូរបស់អង្គការសហ-ប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាល (NGOS) និងអ្នកសិក្សាស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍ជាច្រើនរូបផងដែរ៕
















# ឯកឧត្តម ហេង សុផាន់ណារិទ្ធ អគ្គនាយករង ប.ស.ស. ដឹកនាំក្រុមការងារចូលរួមសិក្ខាសាលាស្តីពីប្រព័ន្ធកិច្ចគាំពារសង្គម សម្រាប់វិស័យកសិកម្មរបស់ប្រទេសបារាំង

នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. និងជាប្រធានក្រុមការងារបច្ចេកទេសគម្រោងកិច្ចគាំពារសង្គមផ្នែកនវានុវត្តន៍សម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (SPIN Project) បានដឹកនាំសមាជិកនៃក្រុមការងារបច្ចេកទេសគម្រោងកិច្ចគាំពារសង្គមផ្នែកនវានុវត្តន៍សម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (SPIN Project) ចូលរួមសិក្ខាសាលាតាមរយៈប្រព័ន្ធអនឡាញស្តីពី ប្រព័ន្ធកិច្ចគាំពារសង្គមសម្រាប់វិស័យកសិកម្មរបស់ប្រទេសបារាំង (The French Social - Protection System for Agricultural Sector)។

សិក្ខាសាលានេះ ធ្វើឡើងក្នុងគោលបំណងដើម្បីបង្ហាញអំពីប្រព័ន្ធកិច្ចគាំពារសង្គមសម្រាប់វិស័យកសិកម្មរបស់ប្រទេសបារាំង និងការពិនិត្យឡើងវិញអំពីបរិបទប្រជាជនកម្ពុជាព្រមទាំងប្រមូលនូវធាតុចូលសំខាន់ៗក្នុងការបង្កើតជាយុទ្ធសាស្ត្រសម្រាប់គ្របដណ្តប់ការការពារលើកសិករ និងកម្មករនិយោជិតក្នុងវិស័យកសិកម្មនៅកម្ពុជា។










គួររំលឹកផងដែរថា៖ អង្គការ GRET បានអនុវត្តគម្រោង SPIN ចាប់តាំងពីខែធ្នូ ឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្ន ដើម្បីគាំទ្រផ្នែកបច្ចេកទេសដល់ ប.ស.ស. ក្នុងគោលបំណងពង្រីករបបសន្តិសុខសង្គមដល់កម្មករនិយោជិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយផ្តោតលើអ្នកបើកម៉ូតូ-រ៉ឺម៉ក ដែលជាសមាជិក នៃសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) និងអ្នកបម្រើក្នុងផ្ទះដែលជាសមា-ជិកសមាគមអ្នកបម្រើការងារតាមផ្ទះ (ADW) នៅរាជធានីភ្នំពេញ។

សូមបញ្ជាក់ថា៖ សិក្ខាសាលាខាងលើសហការរៀបចំឡើងដោយទីស្នាក់ការកណ្ដាលមូលនិធិសង្គមជួយគ្នាទៅវិញទៅមកនៅក្នុងវិស័យកសិកម្ម (Caisse Centrale de la Mutualité Sociale Agricole, CCMSA) និងអង្គការហ្គ្រេត (GRET) ប្រចាំនៅកម្ពុជានៅសាលប្រជុំធំនៃ ប.ស.ស. តាមរយៈប្រព័ន្ធអនឡាញ (Zoom) មានរយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃទី ២២-២៣ ខែមីនា ឆ្នាំ២០២២ ដោយមានអ្នកចូលរួមប្រមាណជាង៤០នាក់៕












# ថ្នាក់ដឹកនាំ ប.ស.ស. ចូលរួម វេទិកាសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី៧៦ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍ វិស័យកសិកម្ម និងជនបទ

ក្រោមការចាត់តាំងពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នាថ្ងៃពុធ ទី២៣ ខែមីនា ឆ្នាំ២០២២ នៅសាលប្រជុំធំ ប.ស.ស. ស្នាក់ការកណ្តាល រាជធានីភ្នំពេញ **ឯកឧត្តម ម៉ែន នរៈឧុធ** អគ្គនាយករង ប.ស.ស. បានដឹកនាំមន្ត្រី ប.ស.ស. ចូលរួម "វេទិកាសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី៧៦" ក្រោមអធិបតីភាព **ឯកឧត្តម សុខ ស៊ីឡូ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ (ក.ក.ជ) តាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting) ។









វេទិកាខាងលើនេះ ត្រូវបានពិភាក្សា និងឈ្វេងយល់លើគន្លឹះសំខាន់ៗ មួយ-ចំនួន រួមមាន៖ (១) ស្វែងយល់ពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលគិតគូរពីអាហារូបត្ថម្ភ (២) ស្តីពី បច្ចុប្បន្នភាពនៃការវាយតម្លៃបឋមស្តីពីសុវត្ថិភាពម្ហូបអាហារ (៣) ស្តីពីការស្ទង់មតិភាគីពាក់ព័ន្ធលើគម្រោងលើកកម្ពស់អាហារូបត្ថម្ភចិញ្ចឹមទារក និងកុមារនៅកន្លែងធ្វើការ (៤) ស្តីពីយុទ្ធសាស្ត្របណ្តាញធុរកិច្ចចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា (២០២១-២០២៥) និង (៥) ស្តីពី របាយការណ៍បឋមនៃការវាយតម្លៃសមត្ថភាពលើទំនាក់ទំនងការផ្លាស់ប្តូរឥរិយាបទសង្គម នៅក្នុងកម្មវិធីអាហារូបត្ថម្ភ។

សូមបញ្ជាក់ថា៖ វេទិកាសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី៧៦ ខាងលើនេះ រៀបចំឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ (ក.ក.ជ) ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាជាច្រើនស្ថាប័ន៕














# ថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមឈ្វេងយល់ស្តីពីរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ

នៅថ្ងៃព្រហស្បត៍ ទី២៧ ខែមករា ឆ្នាំ២០២២ **លោក សុក បូរ៉ា** ប្រធាននាយកដ្ឋានតាវកាលិកសន្តិសុខសង្គមនៃ ប.ស.ស. ក្រោមការចាត់តាំងពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. បានអញ្ជើញធ្វើបទបង្ហាញស្តីពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ នៅសាលសិក្ខាសាលាខាងជើង នៃវិមានព្រឹទ្ធសភា ក្រោមអធិបតីភាព **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំជាច្រើនរូប។

**លោក សុក បូរ៉ា** បានបញ្ជាក់ឲ្យដឹងថា៖ ការរៀបចំឲ្យមានបទបង្ហាញខាងលើនេះ គឺដើម្បីផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ ពិសេសធ្វើការពង្រឹងសេវានៃការផ្តល់តាវកាលិកជូនសមាជិក ប.ស.ស. ដោយបានពន្យល់បញ្ជាក់ឲ្យកាន់តែច្បាស់ពីរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ប័ណ្ណសមាជិក ប.ស.ស. ព្រមទាំងនីតិវិធីនៃការទៅទទួលសេវានៅតាមមន្ទីរពេទ្យដែលជាដៃគូរបស់ ប.ស.ស. ផងដែរ។

សូមបញ្ជាក់ថា៖ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ ត្រូវបានដាក់ឲ្យអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០២១៕







# ពងទាកូនជួយសុខភាព តែបើហ៊ានញ៉ាំខុសនឹងគ្រោះថ្នាក់ដល់សុខភាព!

១-មិនត្រូវញ៉ាំពេលយប់នោះទេ៖ ពងទាកូនជាចំណីពេលល្ងាចនិងពេលយប់ដ៏ពេញនិយមមួយ។ ប៉ុន្តែញ៉ាំវានៅពេលយប់គឺអាចប៉ះពាល់ដល់សុខភាពធ្ងន់ធ្ងរ។ ក្នុងពងទាកូនមួយគ្រាប់មាន ថាមពល ១៨២ កាឡូរី, ប្រូតេអ៊ីន ១៣.៦ក្រាម-លីពីត ១២.៤ ក្រាម កាល់ស្យូម ៨២ មិល្លី-ក្រាម និងកូលេស្តេរ៉ុល៦០០។ ម៉្យាងទៀត ពងទាកូនអាចបណ្តាលឲ្យមានជំងឺលើស-ឈាម និងអាការផ្សេងៗទៀតដូចជា តឹងពោះខ្លាំង និងប៉ះពាល់ដល់ប្រព័ន្ធរំលាយអាហារធ្វើឲ្យចុះខ្សោយ។ ម៉ោងដែលអ្នកគួរញ៉ាំគឺពេលព្រឹក ប៉ុន្តែមិនត្រូវញ៉ាំញឹកញ៉ាប់ពេកទេ។



២-កូនក្មេងមិនគួរឲ្យញ៉ាំពងទាកូនឡើយ៖កូនក្មេងអាយុលើ ៥ ឆ្នាំ ពងទាកូន១គ្រាប់អាចញ៉ាំបានពាក់កណ្តាល ហើយ ១-២ ដងក្នុងមួយសប្តាហ៍។ ការញ៉ាំហួសកម្រិតនឹងធ្វើឲ្យកូនក្មេងលើសវីតាមីន A និងមានបញ្ហាដល់ការលូតលាស់នៃឆ្អឹងផងដែរ។



-លើសពីនេះទៅទៀតអ្នកធាត់ មនុស្សចាស់ អ្នកជំងឺដែលមានសម្ពាធ-ឈាមខ្ពស់ ជំងឺទឹកនោមផ្អែម ជំងឺក្រិនថ្លើម ជំងឺស្ទះសរសៃឈាមបេះដូងគួរតែកំណត់ការញ៉ាំអាហារនេះ។មានតែមនុស្សពេញវ័យដែលមានសុខភាពល្អប៉ុណ្ណោះដែលគួរតែទទួលទាន ពងទាកូនពីរគ្រាប់រៀង-រាល់សប្តាហ៍។

៣-ញ៉ាំពងទាកូនជាមួយខ្ញី៖ ខ្ញីអាចជួយប្រព័ន្ធរំលាយអាហារដើរស្រួល និងជាគ្រឿងផ្សំដ៏ល្អមួយជួយបន្ថយអាការផ្តាសាយ។ដូច្នេះញ៉ាំខ្ញីជាមួយពងទាកូនជួយឲ្យអ្នកស្រួលខ្លួនដោយមិនបារម្ភរឿងមិនរំលាយអាហារ។ ប៉ុន្តែទោះយ៉ាងនេះក្តី ញ៉ាំអាហារនេះត្រឹម ១-២ ដង មួយដង ១-២ គ្រាប់ក្នុងមួយអាទិត្យ គឺគ្រប់គ្រាន់ហើយ៕







# បណ្ដាំ

## អ្នកព្រះភិរម្យភាសា អ៊ូ ហៅង៉ុយ



អ្នកជឿពាក្យចាស់ ជឿចាំឲ្យណាស់ កុំធ្វើបំពារ
អ្នកហ៊ានស្បែកដាច អ្នកខ្លាចស្បែកជា មនុស្សចោរប៉ោបៀ
កុំយកខ្លួនបៀត។

ឃើញឬកគេល្អ ទោះបីមានក្រ យកគេជាញាតិ
គួររាប់អ្នកក្រៅ ផៅអ្នកឯទៀត រាប់រើសមារយាទ
សុចរិតត្រឹមត្រូវ។

រៀនបទរៀនបាទ កុំកោងហួសខ្នាត កុំភ្លាត់ហួសផ្លូវ
កុំភ្លើនភ្លេចម៉ែ កុំប្រែហួសឪ ឃើញចាស់សក់ស្កូវ
កុំសូវមើលងាយ។

បន្ទន់អាត្មា ខ្លាចមេខ្លាចបា ខ្លាចតាខ្លាចយាយ
បម្រើមហាក្សត្រ ប្រយ័ត្នស្ដេចទាយ ពាក្យពិតទំនាយ
រលាយកេរ្តិ៍ឈ្មោះ។

ពាក្យស្ដេចពាក្យគ្រូ មានប្រែមានជូរ កម្រពីរោះ
ជូនទាយឲ្យទាប ជូនទាយឲ្យខ្ពស់ ទាយឲ្យសក្តិយស
ទាយចុះកុំខឹង។

បម្រើមើលភេទ ចំណាំព្រះនេត្រ ហេតុខ្លួនឲ្យដឹង
ខ្លួនខ្ជិលហៃព្រើល លោកមើលសម្លឹង សម្លក់ឲ្យប្រឹង
ខំប្រិតសូត្ររៀន។

បម្រើមើលពុត ប្រាជ្ញាឲ្យមុត ស្មារតីឲ្យមាន
បើខ្លៅឲ្យប្រាជ្ញ បើខ្លាចឲ្យហ៊ាន ចង់បានរបៀន
កុំអៀនកុំខ្មាស់។

ពុតលោកជាធំ ជ្រងោប៉ុនភ្នំ ឯងមើលមិនច្បាស់
បម្រើលោកណា លោកហ្នឹងជាម្ចាស់ លោកស្អប់អ្វីណាស់
ប្រាសចោលឲ្យឆ្ងាយ។

កុំឈមឈរជិត កុំយកធ្វើមិត្ត ភ្លាត់ខ្លួនអន្តរាយ
បើប្រពន្ធកូន បងប្អូនចៅហ្វាយ ឪពុកឬម្ដាយ
ឱនកាយប្រតិបត្តិ៕

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ: ៤១០/២២.ឥត.ជ

ថ្ងៃ ពុធ ១កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០២២

**ជម្រាបមក**

**លោក ហេង សុផាន់ណារិទ្ធ ម្ចាស់អាជីវកម្មព្រឹត្តិបត្រ បេឡាជាតិរបបសន្តិសុខសង្គម**

**កម្មវត្ថុ** ៖ ស្តីពីសំណើសុំការអនុញ្ញាតបន្តសុពលភាពអាជីវកម្មព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម**។

**យោង** ៖-ប្រកាសលេខ៣៥១ព.ម ប្រក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងព័ត៌មាន
-លិខិតលេខ៣១២/២១ ធត.ប្រ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ របស់រដ្ឋបាលរាជធានីភ្នំពេញ
-ពាក្យស្នើសុំ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ របស់លោក **ហេង សុផាន់ណារិទ្ធ**។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកជ្រាបថា រដ្ឋបាលរាជធានីភ្នំពេញអនុញ្ញាតឱ្យលោកបន្តដំណើរការអាជីវកម្មព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ដែលមានទីតាំងស្ថិតនៅអាគារលេខ០៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បន្តពីលិខិតលេខ៣១២/២១ ធត.ប្រ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ របស់រដ្ឋបាលរាជធានីភ្នំពេញ។

ដើម្បីចូលរួមអនុវត្តច្បាប់ ជាពិសេសក្នុងដំណើរការអាជីវកម្មព្រឹត្តិបត្រ រដ្ឋបាលរាជធានីភ្នំពេញស្នើលោក អនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិច្បាប់ ច្បាប់ស្តីពីរបបសារព័ត៌មាន ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា សេចក្តីណែនាំ បទបញ្ជានានាទាក់ទងវិស័យព័ត៌មាន និងសោតទស្សន៍ និងកិច្ចសន្យាអាជីវកម្មព្រឹត្តិបត្រ។

លិខិតអនុញ្ញាតនេះ មានសុពលភាពរយៈពេល ០១(មួយឆ្នាំ) គិតពីថ្ងៃចុះហត្ថលេខាតទៅ ហើយលោកត្រូវស្នើសុំបន្តលិខិតអនុញ្ញាតជាថ្មីឡើងវិញក្នុងរយៈពេល៣០ថ្ងៃមុនលិខិតអនុញ្ញាតនេះផុតសុពលភាព។

ក្នុងករណីលោកមិនអនុវត្តតាមលក្ខខណ្ឌខាងលើ រដ្ឋបាលរាជធានីភ្នំពេញនឹងនិរាករណ៍លិខិតអនុញ្ញាតនេះដោយឥតលក្ខខណ្ឌ។

រដ្ឋបាលរាជធានីភ្នំពេញមានក្តីសង្ឃឹមជឿជាក់លើស្មារតីយកចិត្តទុកដាក់របស់លោក និងអនុវត្តតាមការណែនាំខាងលើដោយការទទួលខុសត្រូវខ្ពស់។

**ជ.អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**
**អភិបាលរង**

**ឃួត ហៃ**

<u>ចម្លងជូន៖</u>
-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌទួលគោក
-មន្ទីរព័ត៌មានរាជធានីភ្នំពេញ
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

# បេឡាជាតិសន្តិសុខសង្គម

**National Social Security Fund**

០២៣ ៨៨ ២៤ ៣៤
០២៣ ៩៩ ៨៤ ១៧
០២៣ ៩៩ ៨៤ ១៨
០២៣ ៩៩ ៨៨ ១៩
០២៣ ៨៨ ២៦ ២៣
១២៨៦ (២៤ម៉ោង/៧ថ្ងៃ)

បេឡាជាតិសន្តិសុខសង្គម
NSSF Official
t.me/nssfcambodia
info@nssf.gov.kh
www.nssf.gov.kh

អគារលេខ៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
(បរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)

